- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧. ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤. ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១០០៤/ ០០៥ .ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២,០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក . ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១១១.៤០០.០០០ រៀល (មួយរយដប់មួយលានបួនរយពាន់រៀលគត់) ពីជំពូក ១១ (ចំណាយអំណើរការរដ្ឋបាល សំភារៈ និងការផ្គត់ផ្គង់តូច) មកជំពូក ១០ (បៀវត្ស និង ប្រាក់បំណាច់) សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង អនុខ័ណ្ឌ របស់ក្រសួង-ស្ថាប័នខាងលើ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់បើកប្រាក់បៀវត្សជូនមន្ត្រីរាជការ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីគោរពជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧៩៥...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

សម្រេច

មាត្រា ១. -

ត្រូវបានបំពាក់ **មេដាយគ្រាក់ស្ថាបនាជាតិ** ចំនួន ០១គ្រឿង ជូនចំពោះលោក **គីម ណាមយ៉ុង** (***Mr.KIM NAM YONG***) ជាគ្រូបង្វឹក នៃ សមាគមអ្នកមុជទឹក នៃ សាធារណរដ្ឋកូរ៉េ ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន អស់ចំនួន ៥.៥១៦ ដុល្លារ សំរាប់ឧបត្ថម្ភដល់ វគ្គបំប៉ននោធាចារ្យ ***SCUBA*** កងទ័ពជើងទឹក នៃ កងយោធពលខេមរភូមិន្ទ ។

មាត្រា ២. -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

B.87

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៨៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅ ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៨/១០៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- បានឃើញអនុក្រឹត្យ លេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការរៀបចំសមាសភាព រចនាសម្ព័ន្ធ តួនាទីភារកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងមន្ត្រី ០៦ រូប នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដូចមានរាយនាមខាងក្រោម :

១- លោក **ហេង ទិដ្ឋា** ជាប្រធាននាយកដ្ឋានស្ថិតិ-ទិន្នន័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
២- លោកស្រី **ណី សុឃីម** ជាប្រធាននាយកដ្ឋានកសិកម្ម
៣- លោក **ស្រ៊ុន ដារិទ្ធិ** ជាប្រធាននាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ
៤- លោក **ហ៊ុង លាងហេង** ជាប្រធាននាយកដ្ឋានធនធានទឹក
៥- លោក **ឈឹម សុខា** ជាប្រធាននាយកដ្ឋានអភិវឌ្ឍន៍ជនបទ
៦- លោកស្រី **គង់ ចន្ថា** ជាប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៨៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខនស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១. -

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១ គ្រឿង ប្រគេនព្រះតេជគុណ **សឿន សេដ្ឋា** ព្រះចៅអធិការវត្តសោបលើ ដែលបានបរិច្ចាគធនធានផ្ទាល់ព្រះអង្គ ជួយកសាងសមិទ្ធផលនៅវត្តសោបលើ ជួយឧបត្ថម្ភគ្រួសារក្រីក្រនៅឃុំសោប ស្រុកព្រៃកប្រសព្វ និង កសាងរបងវត្តហុងឡាំ ក្នុងឃុំអូរឬស្សី ស្រុកក្រចេះ ស្ថិតនៅក្នុងខេត្តក្រចេះ អស់ទឹកប្រាក់ចំនួន ៤០.៨០០ ដុល្លារអាមេរិក ។

មាត្រា ២. -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ធ្នូ ឆ្នាំ២០០៤
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៩៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងធនធានទឹក និង ឧតុនិយម

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ១០រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមជួសជុលស្តារឡើងវិញនូវប្រព័ន្ធស្រោចស្រពអាងទឹកត្រពាំងថ្ម ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ដូចមាន រាយនាមខាងក្រោម :-

ក_មេដាយមាសការងារ :

១-លោក **យឹម ប៊ុនរ៉ុម**	ប្រធានមន្ទីរធនធានទឹក និង ឧតុនិយម ខេត្តបន្ទាយមានជ័យ
២-លោក **គីម ណាន**	អភិបាល ស្រុកភ្នំស្រុក
៣-លោក **គី ឈួន**	អភិបាលរង ស្រុកភ្នំស្រុក
៤-លោក **ចិន ហម**	មេឃុំប៉ោយចារ ស្រុកភ្នំស្រុក

ខ_មេដាយប្រាក់ការងារ :

១-លោក **លី ទុន្នី**	អនុប្រធានមន្ទីរធនធានទឹក និង ឧតុនិយម ខេត្តបន្ទាយមានជ័យ
២-លោក **ខាច់ ហាន់**	ប្រធានការិយាល័យរដ្ឋបាល និង បុគ្គលិក មន្ទីរធនធានទឹក និង ឧតុនិយម ខេត្តបន្ទាយមានជ័យ

៣-លោក **ម៉ក់ ចាន់ថា** ប្រធានការិយាល័យធារាសាស្ត្រ កសិកម្ម មន្ទីរធនធានទឹក និង ឧតុនិយម ខេត្តបន្ទាយមានជ័យ

៤-លោក **ម៉ុន ពៅ** អនុប្រធានការិយាល័យរដ្ឋបាល និង បុគ្គលិក មន្ទីរធនធានទឹក និង ឧតុនិយម ខេត្តបន្ទាយមានជ័យ

៥-លោក **ឃុត ម៉ុនឈៀង** អនុប្រធានការិយាល័យគ្រប់គ្រង និង អភិរក្សធនធានទឹក មន្ទីរធន-ធាន ទឹក និង ឧតុនិយម ខេត្តបន្ទាយមានជ័យ

៦-លោក **គិត សុខឃួន** អនុប្រធានការិយាល័យទឹកស្អាត និង អនាម័យ មន្ទីរធនធានទឹក និង ឧតុនិយម ខេត្តបន្ទាយមានជ័យ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៥៥ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាន្ទវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តបាត់ដំបង

សម្រេច

មាត្រា១.

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូន ឯកឧត្តម អស់លោក ចំនួន ១៤រូប ដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ ក្នុងការបំពេញភារកិច្ច បំរើជាតិ មាតុភូមិ នៅក្នុងស្រុកបាត់ដំបង ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមនេះ :-

១-ឯកឧត្តម ឧត្តមសេនីយ៍ឯក	**ខៀវ សុភ័គ**	អគ្គលេខាធិការ ក្រសួងមហាផ្ទៃ
២-ឯកឧត្តម	**រស់ ឋុរណា**	អគ្គលេខាធិការរង ក្រសួងមហាផ្ទៃ
៣-ឯកឧត្តម ឧត្តមសេនីយ៍ទោ	**គឹម សំណាង**	អនុប្រធានទី១ នាយកដ្ឋានកណ្តាលមធ្យោបាយ ក្រសួងមហាផ្ទៃ
៤-លោក ឧត្តមសេនីយ៍ត្រី	**មាស សាខុន**	អគ្គលេខាធិការរង ក្រសួងមហាផ្ទៃ
៥-លោក ឧត្តមសេនីយ៍ត្រី	**សម សាគុណ**	ប្រធានអធិការដ្ឋានកិច្ចការនគរបាលក្រសួងមហាផ្ទៃ
៦-លោក ឧត្តមសេនីយ៍ត្រី	**ហ៊ុល សត្ថា**	ទីប្រឹក្សារដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

៧-លោក	ញ៉ើម សុខរ៉ាវុធ	ប្រធាននាយកដ្ឋាន នៃ អគ្គលេខាធិការដ្ឋាន ប្រយុទ្ធប្រឆាំងគ្រឿងញៀន
៨-លោក	មាស ម៉ុនធុន	អនុប្រធានរតនាគារជាតិ
៩-លោក	លឹម ចន្ទម៉ៃ	មន្ត្រីរតនាគារជាតិ
១០-លោក	យុត ស៊ូនី	មន្ត្រីរតនាគារជាតិ
១១-លោក	ស៊ីន សំអេច	ប្រធានរតនាគារ ខេត្តបាត់ដំបង
១២-លោក	សៀង ស៊ុគឌីន	អភិបាលស្រុកបាត់ដំបង
១៣-លោក	ម៉ើន ឃាង	អភិបាលរងស្រុកបាត់ដំបង
១៤-លោក	ជេត ទ្រឹត	អភិបាលរងស្រុកបាត់ដំបង

មាត្រា២.

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

231-132

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦៩០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាឲ្យដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តបាត់ដំបង

សម្រេច

មាត្រា១.

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូន អស់លោក លោកស្រី ចំនួន ៦០រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច បំរើជាតិ មាតុភូមិ នៅក្នុងស្រុកបាត់ដំបង ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមនេះ :-

ក. មេដាយមាសការងារ :

១-លោក	ឈឹង រ៉ែ	ប្រធានមន្ទីរ ស្រុកបាត់ដំបង
២-លោកអនុសេនីយ៍ឯក	ឆួម រ៉ា	អធិការ នគរបាលស្រុកបាត់ដំបង
៣-លោកអនុសេនីយ៍ទោ	ឡាច ឡុង	អធិការរង នគរបាលស្រុកបាត់ដំបង
៤-លោកអនុសេនីយ៍ទោ	ចាន់ រ៉ា	អធិការរង នគរបាលស្រុកបាត់ដំបង

ខ. មេដាយប្រាក់ការងារ :

១-លោក	នូ ញ៉ី	អនុប្រធានមន្ទីរ ស្រុកបាត់ដំបង
២-លោក	ថោង នី	ប្រធានការិយាល័យសេដ្ឋកិច្ច សាលាស្រុកបាត់ដំបង

៣-លោកអនុសេនីយ៍ត្រី	ម៉ែន សេងអៀង	នាយផ្នែកសណ្តាប់ធ្នាប់ នគរបាលស្រុកបាត់ដំបង
៤-លោក	ឆាន ច័ន្ទថយ	ប្រធានការិយាល័យរដ្ឋបាលទូទៅ សាលាស្រុក
៥-លោក	យស សរ	មន្ត្រីការិយាល័យរដ្ឋបាលទូទៅ សាលាស្រុក
៦-លោកស្រី	ញឹក សារគន្ធ	សមាជិកក្រុមប្រឹក្សាឃុំទួលតាឯក
៧-លោក	គួច ថុន	មន្ត្រី សាលាខេត្ត
៨-កញ្ញា	ឈឿន មុំ	ប្រធានការិយាល័យកិច្ចការនារីនិង អតីតយុទ្ធជនស្រុក
៩-លោក	ស្វួន ឆន្ធា	ប្រធានការិយាល័យ ពត៌មានស្រុក
១០-លោកអនុសេនីយ៍ត្រី	គាត លី	នាយប៉ុស្តិ៍នគរបាល រដ្ឋបាល ឃុំចំការសំរោង
១១-លោកអនុសេនីយ៍ត្រី	ឃុត វណ្ណៈ	នាយប៉ុស្តិ៍នគរបាល រដ្ឋបាល ឃុំស្លាកែត
១២-លោកអនុសេនីយ៍ត្រី	គឹម ថេងឌី	នាយប៉ុស្តិ៍នគរបាល រដ្ឋបាល ឃុំក្តុលដូនទាវ
១៣-លោកអនុសេនីយ៍ត្រី	សាន សាម៉ន	នាយប៉ុស្តិ៍នគរបាល រដ្ឋបាល ឃុំ វត្តគរ
១៤-លោកអនុសេនីយ៍ត្រី	សំ សុខា	នាយប៉ុស្តិ៍នគរបាល រដ្ឋបាល ឃុំអូរម៉ាល់
១៥-លោក	សារិត ឆន	សមាជិកក្រុមប្រឹក្សា ឃុំទួលតាឯក
១៦-លោក	ស្វួន សុខេន	សមាជិកក្រុមប្រឹក្សា ឃុំស្វាយប៉ោ
១៧-លោក	ស៊ិន សឿត	ជំទប់ទី១ ឃុំអូរម៉ាល់
១៨-លោក	ស្វួន សារិន	សមាជិកក្រុមប្រឹក្សា ឃុំរតនះ
១៩-លោក	ម៉ែន ឆន	សមាជិកក្រុមប្រឹក្សា ឃុំវត្តគរ
២០-លោក	ហោ ឃីម	សមាជិកក្រុមប្រឹក្សា ឃុំអូរចារ
២១-លោក	សេង ច័ន្ទលី	សមាជិកក្រុមប្រឹក្សា ឃុំចំការសំរោង

គ-មេដាយសេវាការងារ ៖

១-លោក	ភឿ សុផា	នាយរងផ្នែកសណ្តាប់ធ្នាប់ នគរបាលស្រុក
២-លោក	ឌី សារិត	មន្ត្រីនគរបាលស្រុក
៣-លោក	ស្វាយ គិរម្យ	មន្ត្រីនគរបាលស្រុក
៤-លោក	គុជ បុផា	មន្ត្រីនគរបាលស្រុក
៥-លោក	ឆាន់ ចាន់ប៊ុណ្ណា	មន្ត្រីនគរបាលស្រុក
៦-លោក	កេត សេរីរតន៍	មន្ត្រីនគរបាលស្រុក
៧-អ្នកស្រី	វង្ស សុផល	មន្ត្រីការិយាល័យរដ្ឋបាលទូទៅ សាលាស្រុក
៨-លោក	សុវណ្ណ ធឿន	ស្មៀនឃុំទួលតាឯក
៩-អ្នកស្រី	ហុង សុគន្ធា	ស្មៀនឃុំស្វាយប៉ោ
១០-លោក	គង់ សេរីវិទ្ធិ	ស្មៀនឃុំចំការសំរោង
១១-លោក	ណយ សារះវត	ស្មៀនឃុំវត្តគរ
១២-លោក	អ៊ុច ថាំង	ស្មៀនឃុំអូរម៉ាល់
១៣-លោក	នូ ចន្ទ្រី	ស្មៀនឃុំអូរចារ
១៤-លោក	ខេស យឿន	សមាជិកក្រុមប្រឹក្សា ឃុំព្រែកព្រះស្តេច

១៥-លោក	**ឈន់ ហ៊ិន**	សមាជិកក្រុមប្រឹក្សា ឃុំព្រែកព្រះស្តេច
១៦-លោក	**ឃុយ ឈើន**	សមាជិកក្រុមប្រឹក្សា ឃុំរតនៈ
១៧-លោក	**អ៊ើន ឈាំ**	សមាជិកក្រុមប្រឹក្សា ឃុំអូរចារ
១៨-លោក	**នួច អ៊ឺម**	សមាជិកក្រុមប្រឹក្សា ឃុំគ្គលដូនទាវ
១៩-លោក	**រឃួន រ៉ុន**	សមាជិកក្រុមប្រឹក្សា ឃុំគ្គលដូនទាវ
២០-លោក	**តៀក ក្រឡាញ**	សមាជិកក្រុមប្រឹក្សា ឃុំស្លាកែត
២១-លោក	**និច សារមេត**	នាយកអនុវិទ្យាល័យសោហ៊ី ស្រុកបាត់ដំបង
២២-លោក	**បេង ហួន**	មន្ត្រីសាលាស្រុក
២៣-លោក	**សេក នួន**	មន្ត្រីសាលាស្រុក
២៤-លោក	**ប៉ែន ធីន**	មន្ត្រីសាលាស្រុក
២៥-លោក	**ពៅ ម៉ៅល**	មន្ត្រីសាលាស្រុក
២៦-លោក	**នុយ អ៊ឿត**	មន្ត្រីសាលាស្រុក
២៧-លោក	**ដាន់ សុខុន**	មន្ត្រីសាលាស្រុក
២៨-លោក	**សៀន វ៉ាត់**	មន្ត្រីសាលាស្រុក
២៩-លោក	**អេត ផល**	មន្ត្រីសាលាស្រុក
៣០-លោក	**ទ្រាំ សំអាន**	មន្ត្រីការិយាល័យរដ្ឋបាលទូទៅ សាលាស្រុក
៣១-លោកអនុសេនីយ៍ត្រី	**ឡាយ ដាន្នី**	នាយប៉ុស្តិ៍នគរបាល រដ្ឋបាល ឃុំស្វាយប៉ោ
៣២-លោកអនុសេនីយ៍ត្រី	**លួង រលេង**	នាយប៉ុស្តិ៍នគរបាល រដ្ឋបាល ឃុំព្រែកព្រះស្តេច
៣៣-លោកអនុសេនីយ៍ត្រី	**នួន សារិត**	នាយប៉ុស្តិ៍នគរបាល រដ្ឋបាល ឃុំទួលតាឯក
៣៤-លោកអនុសេនីយ៍ត្រី	**ញៀប ម៉ាន់នី**	នាយរងប៉ុស្តិ៍នគរបាល រដ្ឋបាល ឃុំអូរចារ
៣៥-លោកអនុសេនីយ៍ត្រី	**សោ សុខុន**	នាយប៉ុស្តិ៍នគរបាល រដ្ឋបាល ឃុំរតនៈ

មាត្រា២.

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

233–235

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៩១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខនស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១. -

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២ គ្រឿង ជូនសប្បុរសជនចំនួន ០២ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងព្រះវិហារ នៅវត្តព្រះជ័យចេស្តា ហៅវត្តប្បៀក ស្ថិតនៅក្នុងឃុំជាន់ញឹម ស្រុកប្រាសាទ-បល្ល័ង្ក ខេត្តកំពង់ធំ ដូចមានរាយនាមខាងក្រោម ÷

១-លោក **សុខ ស៊ុនលីន** សប្បុរសជននៅខេត្តសៀមរាប ថវិកា ៣៥.០០០ USD

២-ឧបាសិកា **ឡេង ខឹម** សប្បុរសជននៅខេត្តសៀមរាប ថវិកា ១២.០០០ USD

មាត្រា ២. -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី … ខែ ធ្នូ ឆ្នាំ ២០០៤

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៩៥២ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១. -

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងអគារសិក្សា ចំនួន ០៦ខ្នង មាន២៤បន្ទប់ បំពាក់សំភារៈសិក្សាគ្រប់គ្រាន់ និងធ្វើបង្គន់អនាម័យ នៅអនុវិទ្យាល័យតារ៉ាង សាលាបឋមសិក្សា ពន្លាជ័យ ល្បើកស្វាយ ដំណាក់កកោះ នាងកេត ត្រពាំងភាសន៍ និង សាលាមត្តេយ្យ អូរអំបិល ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ចំណាយអស់ទឹកប្រាក់សរុប ចំនួន ១០៨.៨៧៧,០១ ដុល្លារ ដូចមានរាយនាមខាងក្រោមនេះ :-

១-លោក **អ៊ុច ម៉ូដ**	អគ្គនាយក អង្គការកុមារមេត្តា ប្រទេសបារាំង
២-លោក **បេណារូអ៊ា ប្រ៊ូខំប្រ៊ីះ**	នាយក អង្គការកុមារមេត្តា ប្រចាំអាស៊ី
៣-លោក **ម៉ាតាំខ ម៉ុំខឌីយោ**	នាយក អង្គការកុមារមេត្តា ប្រចាំកម្ពុជា

មាត្រា ២. -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
B.015 -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៩៣ អនក្រ.តត

អនុក្រឹត្យ
ស្ដីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ១៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាង ព្រះវិហារ កុដិ ស្រះទឹក ជណ្ដើរថ្ម ព្រះពុទ្ធបដិមា ក្លោងទ្វារ សួនសោភ័ណភាព ជួសជុលសាលាធម្មសភា និង សមិទ្ធផលមួយចំនួនទៀត នៅក្នុងវត្តស្វាយជាតិ ឃុំរាងកេសី ស្រុកសង្កែ ខេត្តបាត់ដំបង ដូចមាននាមខាងក្រោម :-

ក.មេដាយមាសស្ថាបនាជាតិ :

១-លោកស្រី **អ៊ុច ស៊ីវណ្ណត** សប្បុរសជននៅខេត្តបាត់ដំបង ទឹកប្រាក់ចំនួន ១១.៧៣៤ ដុល្លារ
២-លោក **និត្យ សារឿន** សប្បុរសជននៅខេត្តបាត់ដំបង ទឹកប្រាក់ចំនួន ១០.២៥០ ដុល្លារ
៣-លោក **ស្រី នៅ** សប្បុរសជននៅខេត្តបាត់ដំបង ទឹកប្រាក់ចំនួន ១០.១៥០ ដុល្លារ
៤-លោកស្រី **ស៊ុន សុម៉ឺន** សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ១០.០៧២ ដុល្លារ
៥-លោក **ម៉ាន់ ឡើប** សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ១០.០៥០ ដុល្លារ

ខ.មេដាយប្រាក់ស្ថាបនាជាតិ :

១-ឧបាសិកា **កែវ ហោ** សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ៥.២០០ ដុល្លារ
២-លោកស្រី **សេខ សុខ** សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ៥.១២៥ ដុល្លារ

៣-លោក **ញៀវ យ៉ាង** សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ៥.២១២ ដុល្លារ

៤-លោក **កែម សំអួន** សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ៥.១៥០ ដុល្លារ

គ-មេដាយសេរីវឌ្ឍស្ថាបនាជាតិ :

១-ឧបាសិកា **ឈក គីម** សប្បុរសជននៅខេត្តបាត់ដំបង ទឹកប្រាក់ចំនួន ២.០០០ ដុល្លារ

២-ឧបាសិកា **កែម ហូ** សប្បុរសជនខ្មែរនៅប្រទេសស្វីស ទឹកប្រាក់ចំនួន ១.៧៥០ ដុល្លារ

៣-ឧបាសិកា **លី ឃុននី** សប្បុរសជននៅក្រុងភ្នំពេញ ទឹកប្រាក់ចំនួន ១.០០០ ដុល្លារ

៤-ឧបាសិកា **ហួរ ហួយ** សប្បុរសជនខ្មែរនៅប្រទេសស្វីស ទឹកប្រាក់ចំនួន ១.០០០ ដុល្លារ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។៕

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច /
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦៥៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣០៥

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី *WANIBUCHI MIEKO* សប្បុរសជនជប៉ុន ដែលបានផ្តល់ថវិកា ចំនួន ២៥.៧២០ ដុល្លារអាមេរិក សំរាប់ជួយ កសាងអគារសិក្សា ០១ខ្នង បំពាក់ដោយសម្ភារៈគ្រប់គ្រាន់ រួមទាំងអណ្តូងទឹកមួយ ជូនសាលាបឋមសិក្សាសាមគ្គីបឹងស្នាច់ ក្នុងភូមិព្រិច ឃុំស្តី ក ស្រុកបាភ្នំ ខេត្តព្រៃវែង ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

B.31

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៩៥ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា ១. ~

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនលោក ***BERNARD KRISHER*** ប្រធានអង្គការ ***AAFC*** ដែលបានជួយកសាងសាលារៀន ចំនួន ១៤ខ្នង មាន ៥៦ បន្ទប់ នៅខេត្តរតនគីរី ដែលអាចទទួលកុមារអោយចូលរៀន បានចំនួន ២.២៤០ នាក់ ចំណាយអស់ថវិកា ចំនួន ១០៦.០០០ ដុល្លារ ។

មាត្រា ២. ~

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

B 57

ជាបន្ទាន់ ក្នុងករណីមានការយឺតយ៉ាវស្ថិតនៅ ចន្លោះពីថ្ងៃទី ០១ ខែ មករា ដល់ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៥ នោះ កាលបរិច្ឆេទនៃការបង់ក៏ត្រូវចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ ដែរ ។ ផ្ទុយទៅវិញ ប្រសិនបើហួសកាលកំណត់ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៥ ហើយ សាលាខេត្ត ក្រុង នៅតែពុំទាន់បានបង់ទេនោះ គឺរតនាគារខេត្ត ក្រុងត្រូវម្ចាស់ការផ្ទេរដោយស្វ័យប្រវត្តិចូលជាចំណូលថវិការដ្ឋ ហើយត្រូវជូនដំណឹងទៅសាលាខេត្ត ក្រុងអោយបានជ្រាប ។ កាលបរិច្ឆេទនៃការផ្ទេរនេះ ក៏ត្រូវចាត់ទុកថាជាកិច្ចប្រតិបត្តិការថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ ដែរ ។

៤. កិច្ចប្រតិបត្តិការនិយ័តភាវូបនីយកម្មរបស់រតនាគារ សំរាប់ថវិកាខេត្ត ក្រុង ឆ្នាំ ២០០៤ ត្រូវបន្តរហូតដល់ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៥ ។ កិច្ចប្រតិបត្តិការនេះ ត្រូវបានពិនិត្យកត់ត្រាជាលេខនាបន្ថែមទៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលទាក់ទងទៅនឹង ៖

- ការកត់ត្រាជាស្ថាពរនៃចំណូល ឬនៃចំណាយ ដែលបានពិនិត្យកត់ត្រាជាលេខនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ ជាអាទិ៍ ចូលគណនីកត់ត្រាបណ្តោះអាសន្ន ។
- អាណត្តិនិយ័តភាវូបនីយកម្ម ដែលទាក់ទងដល់ចំណាយដែលបានទូទាត់ដោយរដ្ឋទេយ្យបុរេប្រទានមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ ។
- ការកែប្រែលេខនាខុស ។

៥. ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥ តទៅ រាល់កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាខេត្ត ក្រុងឆ្នាំថ្មី ត្រូវកត់ត្រាចូលក្នុងគណនីថវិកាខេត្ត ក្រុងឆ្នាំ ២០០៥ ។

៦. ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥ រតនាគារខេត្ត ក្រុង និងក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុង ត្រូវដំណើរការបូកសរុបនិងផ្ទៀងផ្ទាត់អំពីការអនុវត្តចំណូល ចំណាយថវិកាខេត្ត ក្រុង ឆ្នាំ ២០០៤ ដោយរតនាគារខេត្ត ក្រុងត្រូវបង្កើតតារាងតុល្យភាពគណនីប្រចាំឆ្នាំ និងក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុងត្រូវធ្វើតារាងបូកសរុបចំណូល ចំណាយថវិកាខេត្ត ក្រុងតាមមាតិកាថវិកា រួចធ្វើកំណត់បង្ហាញដាក់ជូនឯកឧត្តមអភិបាលខេត្ត ក្រុងពិនិត្យសំរេចនិងចុះហត្ថលេខា។ អភិបាលខេត្ត ក្រុងត្រូវធ្វើលិខិតបញ្ជូនតារាងតុល្យភាពគណនីប្រចាំឆ្នាំ តារាងបូកសរុបចំណូល ចំណាយ និងកំណត់បង្ហាញខាងលើទៅក្រសួងមហាផ្ទៃចំនួន ០១ច្បាប់ និងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ០២ច្បាប់ អោយបានមុនថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៥ ដើម្បីនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការបូកសរុប និងរៀបចំនូវរបាយការណ៍សំរេចទូទាត់ថវិកាខេត្ត ក្រុងរួមមួយ ដើម្បីដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ ។

អភិបាលខេត្ត ក្រុង ត្រូវយកចិត្តទុកដាក់អនុវត្តអោយបានតាមការកំណត់ដូចខាងលើ ដើម្បី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានលទ្ធភាពធ្វើការបូកសរុប រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកា ទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសំរេច និងរដ្ឋសភា ព្រឹទ្ធសភា ពិនិត្យអនុម័តអោយបានទាន់ពេលវេលា ។/.

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៤

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន:

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ធនាគារជាតិ
- សាលាខេត្ត ក្រុង
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ក្រុង
- ធនាគារខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

លេខកូដ............

តារាងបូកសរុបចំណូលថវិកាខេត្ត ក្រុង

សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤

តារាងឧបសម្ព័ន្ធ១

ជំពូក	ប្រការ	កថាខណ្ឌ	អនុកថាខណ្ឌ	បរិយាយ ចំណាត់ថ្នាក់ចំណូល	ច្បាប់ ហិរញ្ញវត្ថុដើមឆ្នាំ	អនុវត្ត ជាក់ស្តែង	សមាមាត្រ ប្រៀបធៀប	សេចក្តីផ្សេងៗ
				១	២	៣	៤=៣ / ២	
				សរុបរួម				

ហត្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា	ហត្ថលេខា
អភិបាលខេត្ត ក្រុង	ប្រធានរតនាគារខេត្ត ក្រុង	ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	អ្នកធ្វើតារាង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

តារាងបូកសរុបចំណាយថវិកាខេត្ត ក្រុង

លេខកូដ............

សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤

តារាងឧបសម្ព័ន្ធ២

ជំពូក	ប្រការ	កថាខណ្ឌ	អនុកថាខណ្ឌ	បរិយាយ ចំណាត់ថ្នាក់ចំណាយ	ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ	ឥណទានអនុញ្ញាត	អនុវត្តជាក់ស្តែង	សមាមាត្រប្រៀបធៀប	សេចក្តីផ្សេងៗ
				១	២	៣	៤	៥-៤/៣	
				សរុបរួម					

ហត្ថលេខា និង ត្រា
អភិបាលខេត្ត ក្រុង

ហត្ថលេខា និង ត្រា
ប្រធានរតនាគារខេត្ត ក្រុង

ហត្ថលេខា និង ត្រា
ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា
អ្នកធ្វើតារាង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. [illegible] MOC / M 2004

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៤

ប្រកាស

ស្តីពីស្ថានភាពរោងចក្រកាត់ដេរ

SAM HAN CAMBODIA FABRIC CO., LTD.

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញការចាំបាច់របស់ក្រសួង

សម្រេច

ប្រការ ១ : ចាត់ទុកថាបាន **បិទទ្វារជាបណ្តោះអាសន្ន** រោងចក្រកាត់ដេរសំលៀកបំពាក់ SAM HAN CAMBODIA FABRIC CO., LTD. ដែលគ្មានសកម្មភាពចំពោះមុខដោយមានមូលហេតុផ្សេងៗ ប៉ុន្តែ ឧបករណ៍ផលិតកម្ម និង គ្រឿងម៉ាស៊ីននៅរក្សាដដែលហើយកម្មករត្រូវបានបញ្ឈប់ពីការងារជាបណ្តោះអាសន្ន ។ រោងចក្រកាត់ដេរសំលៀកបំពាក់នោះនឹងត្រូវលុបចេញពីតារាង GSP នៃអ្នកមានសិទ្ធនាំចេញនៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។ ការបែងចែកកូតាផ្សេងៗ (បើមាន) នឹងត្រូវផ្អាក ។ រោងចក្រខាងលើនេះ អាចទទួលបានសិទ្ធ នាំចេញសាជាថ្មី ប្រសិនបើរោងចក្រនោះបន្តសកម្មភាពរបស់ខ្លួនវិញក្នុងរយៈពេល ០៦ ខែបន្ទាប់ ។

ប្រសិនបើរោងចក្រនោះមិនបានបន្តសកម្មភាពរបស់ ខ្លួនក្នុងរយៈពេល ២ ខែបន្ទាប់ រោងចក្រនោះនឹងត្រូវចាត់ទុកថាបានបិទទ្វារជាស្ថាពរ ។ ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មរបស់គេនឹងត្រូវឆូតពណ៌ក្រហម និង ចារថាបាន បិទទ្វារ ។

ប្រការ ២ : ការស៊ើបអង្កេតបន្ថែមទៀតនឹងត្រូវធ្វើឡើងដោយ នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម . នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , នាយកដ្ឋាននិតិកម្ម ទាក់ទិនបំណុល និង ការទទួលខុសត្រូវផ្សេងៗនៃរោងចក្រដែលមានឈ្មោះខាងលើចំពោះតតីយជននៅកម្ពុជា ព្រមទាំងបំណុលរបស់គេចំពោះច្បាប់ និង បទបញ្ញត្តិកម្ពុជា ។

ប្រការ ៣ : អគ្គនាយកបច្ចេកទេស, នាយិកាខុទ្ទកាល័យ, ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម. ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋាននិតិកម្ម និង រោងចក្រដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

<u>ចម្លងជូន</u> :

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី *ស ខេង*
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី *លោ ណាំហុង*
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវៈនិតិសម្បទា
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងប៉ារីស
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 (Kingdom of Cambodia)
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 933 323 / 881223 Facsimile: (855-23) 426396

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ២៦០ MOC / M 2004

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៤

ប្រកាស

ស្តីពីការប្រគល់ភារកិច្ចបន្ថែមជូន នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : ប្រគល់ភារៈកិច្ចបន្ថែមជូននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ឱ្យទទួលខុសត្រូវក្នុងការពិនិត្យ និងផ្តល់វិញ្ញាបនប័ត្រប្រភពដើមទំនិញ ទំរង់ធម្មតា (Certificate of Origin " C\O " Form N) វិញ្ញាបនប័ត្រប្រភពដើមទំនិញ ទំរង់អា (Certificate of Origin " C\O " Form A) សំរាប់ នាំចេញទំនិញគ្រប់ប្រភេទ ទៅកាន់សហគមន៍អឺរ៉ុប ។

ប្រការ ២ : ការផ្តល់វិញ្ញាបនប័ត្រប្រភពដើមទំនិញ ទំរង់ធម្មតា (C\O Form N) និងទំរង់អា (C\O Form A) ត្រូវអនុវត្តទៅតាមបែបបទ ដែលមានស្រាប់របស់ក្រសួងពាណិជ្ជកម្ម និងស្រប តាមបញ្ញត្តិ ផ្សេងៗ ដែលកំណត់ដោយសហគមន៍អឺរ៉ុប ។

ប្រការ ៣ : បទបញ្ញត្តិទាំងឡាយណា ដែលមានន័យផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៤ : អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស នាយិកាខុទ្ទកាល័យ ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស និងប្រធាននាយកដ្ឋានពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម_ប្រសិទ្ធ

<u>កន្លែងទទួល:</u>

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- គ្រប់អង្គភាពចំណុះ ក្រសួងពាណិជ្ជកម្ម
- គ្រប់ស្ថានតំណាងពាណិជ្ជកម្មកម្ពុជា ប្រចាំនៅក្រៅប្រទេស
- គ្រប់មន្ទីរពាណិជ្ជកម្ម ខេត្ត-ក្រុង
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ
- រាជកិច្ច ៤